ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ :.....០២២/១៨.....ក.ប/ស.ជ.ណ.ខ.ល

# សេចក្តីជូនដំណឹង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដល់ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថានទាំងអស់ដែលស្ថិតក្នុងដែនអនុវត្តនៃច្បាប់ស្តីពីការងារបានជ្រាបថា ដើម្បីបង្កលក្ខណៈងាយស្រួលដល់បងប្អូនកម្មករនិយោជិតក្នុងការចូលរួមបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ ខាងមុខ សូមម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថានទាំងអស់ ខិតខំរៀបចំបើកប្រាក់ឈ្នួលជូនកម្មករនិយោជិតឱ្យបានមុនថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៨។ បើពុំមានលទ្ធភាពបើកប្រាក់ឈ្នួលបានទាន់ពេលទេ សូមអនុញ្ញាតឱ្យកម្មករនិយោជិតទទួលប្រាក់បុរេប្រទានយ៉ាងតិច ៥០% (ហាសិបភាគរយ) មុនថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៨។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា អស់លោក លោកស្រីជាម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថានទាំងអស់ នឹងអនុវត្តបានត្រឹមត្រូវតាមសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធភាព។

ថ្ងៃ ចន្ទ ១២រោច ខែ បឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០១៨
រដ្ឋមន្ត្រី

អ៊ិត សំហេង

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត
  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- សមាគមនិយោជក
- សហព័ន្ធសហជីព កម្មករនិយោជិត
  "ដើម្បីជ្រាប និងអនុវត្ត"
- ឯកសារ-កាលប្បវត្តិ